ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៣៤៣៥ សហវ.ជវ

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ ២០១០

គោរពជូន
ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម

**កម្មវត្ថុ:** សំណើសុំគោលការណ៍ចំណាយថវិកាជំពូក ២១ « គម្រោងវិនិយោគផ្ទាល់» ជូននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ នៃក្រសួងធនធានទឹកនិងឧតុនិយម ចំនួន ២.៤៧៥.៥០០.១៥៩រៀល និងបុរេប្រទានថវិកាចំនួន ៤០% សម្រាប់ការងារជួសជុលទំនប់អាងទឹកអូរចាប ស្ថិតក្នុងឃុំកំភុន ស្រុកសេសាន ខេត្តស្ទឹងត្រែង ។

**យោង:**
- ចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១០ លើលិខិតលេខ ២២៤ សហវ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- លិខិតលេខ ៩៦៤ ធទឧ ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១០ របស់ក្រសួងធនធានទឹកនិងឧតុនិយម។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ សូមជម្រាបឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យល់ព្រមផ្តល់ជានាចំណាយជូនចំនួន ២.៣៤៣.០០០.០០០រៀល (ពីរពាន់បីរយសែសិបបីលានរៀលគត់) ដោយប្រើប្រាស់ឥណទានថវិកាជំពូក ២១ « គម្រោងវិនិយោគផ្ទាល់» សម្រាប់ឲ្យនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ នៃក្រសួងធនធានទឹកនិងឧតុនិយម អនុវត្តការងារជួសជុលទំនប់អាងទឹកអូរចាប ក្នុងឃុំកំភុន ស្រុកសេសាន ខេត្តស្ទឹងត្រែង រួមមាន ៖

- ជួសជុលទំនប់អាងទឹកអូរចាប ប្រវែង ៨០០ម
- សាងសង់ផ្លូវភ្ជាប់ពីទំនប់អូរចាបមកទំនប់អូរពូក ប្រវែង ១.៨៦០ម
- ស្តារប្រឡាយនាំទឹកលើទំនប់អូរចាបមកទំនប់អូរពូក ប្រវែង ៣.០០០ម
- ជួសជុលសំណង់ស្ទាក់ទឹកលើប្រឡាយនាំទឹក ចំនួន មួយកន្លែង
- ជួសជុលសំណង់បញ្ចេញទឹកលើប្រឡាយនាំទឹក ចំនួន មួយកន្លែង
- ជួសជុលសំណង់ទ្វារទឹកលើប្រឡាយអូរចាប ចំនួន មួយកន្លែង
- សាងសង់សំណង់លូឆ្លងផ្លូវលើប្រឡាយនាំទឹក ចំនួន មួយកន្លែង
- សាងសង់សំណង់បង្ហៀរដោះទឹក ចំនួន មួយកន្លែង

សេចក្តីដូចបានជម្រាបខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ ។
សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

**ចម្លងជូន**
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- សាលាខេត្តស្ទឹងត្រែង
- នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុក្រសួងធនធានទឹកនិងឧតុនិយម «ដើម្បីអនុវត្ត»
- ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
Nº 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
www.mef.gov.kh
ទូរស័ព្ទ ៈ ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ ៈ ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax: 855-23-427 798
mef_adm@yahoo.com